00649246

E51/5/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 03 / 2011
ម៉ោង (Time/Heure): 9:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

---

**សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំពន្យារពេល និងសុំបន្ថែមចំនួនទំព័រដើម្បីដាក់នូវចម្លើយតបរួមទៅនឹងអញ្ញត្រកម្ម**

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS

ផាត់ ពៅស៊ាង
Diana ELLIS
សា សូវ៉ាន
Jaques VERGÈS
Philippe GRÉCIANO

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ។

**បានឃើញ** សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់ចម្លើយតបទៅនឹងអញ្ញត្រកម្មបឋមរបស់ជនជាប់ចោទ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១១ (ឯកសារ E51/5/1) ដែលបានស្នើសុំពន្យារពេលរហូតដល់ថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០១១ ដើម្បីដាក់នូវចម្លើយតបទៅនឹងអញ្ញត្រកម្មទាំងអស់ និងបានស្នើសុំបន្ថែមចំនួនទំព័រសម្រាប់ការឆ្លើយតបរហូតដល់ចំនួន ៤០ ទំព័រ ("សំណើរបស់សហព្រះរាជអាជ្ញា")។

**បានឃើញផងដែរ** នូវ "សំណើសុំបន្ថែមចំនួនទំព័រដើម្បីឆ្លើយតបរួមទៅនឹងអញ្ញត្រកម្មរបស់ជនជាប់ចោទទាំងអស់" របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ ២០១១ (ឯកសារ E51/5/2) ដែលសំណើនោះបានស្នើសុំបន្ថែមចំនួនទំព័ររហូតដល់ ២៥ ទំព័រ (ជាភាសាអង់គ្លេស ឬបារាំង) និង៥០ ទំព័រ(ជាភាសាខ្មែរ) ដើម្បីឆ្លើយតបរួមទៅនឹងអញ្ញត្រកម្មរបស់ជនជាប់ចោទទាំងអស់ ("សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី")។

**ដោយពិចារណា** ទៅលើចម្លើយតបរបស់មេធាវីការពារ អៀង ធីរិទ្ធ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១១ (ឯកសារE51/5/2) ដែលបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់ចម្លើយតបទៅនឹងអញ្ញត្រកម្មបឋមរបស់ជនជាប់ចោទ ដោយមេធាវីបានលើកនូវសេចក្តីណែនាំរបស់អង្គជំនុំជម្រះជូនចំពោះភាគីដែលបានចេញកន្លងមក (ឯកសារ E51) និងបានជំទាស់ទៅនឹងសំណើ

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តចិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9 ។

របស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងការឆ្លើយតបរបស់មេធាវីការពារ អៀង ធីរិទ្ធ វិញនៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១ (ឯកសារ E51/5/1/2 )។

**ដោយពិចារណាផងដែរ** ទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះដែលបានចេញជាបន្តបន្ទាប់ចំពោះភាគី ហើយដែលអង្គជំនុំជម្រះបានអនុញ្ញាតឱ្យក្រុមមេធាវីការពារជនជាប់ចោទចំនួនពីរក្រុមបន្ថែមនូវចំនួនទំព័រនៃអញ្ញត្រកម្មរហូតដល់ ៣៥ ទំព័រ (ជាភាសាអង់គ្លេស ឬភាសាបារាំង) និងបានពន្យារកាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់អញ្ញត្រកម្មរហូតដល់ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និងដល់ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ (ឯកសារ E51/1 និង E51/5) ។

**ហេតុដូច្នេះសម្រេច**

**អនុញ្ញាត** តាមសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអនុញ្ញាតឱ្យមេធាវីនាំមុខដាក់នូវចម្លើយតបរួមទៅនឹងអញ្ញត្រកម្មរបស់ជនជាប់ចោទទាំងអស់ត្រឹម ២៥ ទំព័រ ជាភាសាអង់គ្លេស ឬបារាំង និង៥០ ទំព័រ ជាភាសាខ្មែរ នៅត្រឹមថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ ដូចដែលបានកំណត់រួចហើយ។

**អនុញ្ញាត** ឱ្យសហព្រះរាជអាជ្ញាដាក់នូវចម្លើយតបរួមទៅនឹងអញ្ញត្រកម្មរបស់ជនជាប់ចោទទាំងអស់ដោយមិនឱ្យលើសពី ៣៥ ទំព័រ (ជាភាសាអង់គ្លេស ឬភាសាបារាំង) និង ៧០ ទំព័រ (ជាភាសាខ្មែរ) ត្រឹមថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ (ជាពីរភាសាផ្លូវការរបស់ អ.វ.ត.ក ដែលក្នុងនោះមួយភាសាគឺជា ភាសាខ្មែរ)។ ។

**សូមបញ្ជាក់ថា** អង្គជំនុំជម្រះមិនតម្រូវឱ្យមេធាវីការពារជនជាប់ចោទធ្វើការឆ្លើយតបទៅនឹងចម្លើយតបទាំងនេះឬធ្វើការឆ្លើយតបទៅនឹងអញ្ញត្រកម្មដែលបានដាក់ដោយមេធាវីការពារជនជាប់ចោទផ្សេងទៀតឡើយ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**